

# ព្រះបាទអសោក និង ព្រះនាងអសន្ធិមិត្តា

## STORY OF KING AKSAOK AND THE QUEEN AKSANTHIMETT A



មានព្រះបច្ចេកពុទ្ធជាច្រើនព្រះអង្គគង់នៅលើភ្នំគន្ធមាទន៍។ ក្នុងក្រុមព្រះបច្ចេកពុទ្ធទាំងនោះមាន១ព្រះអង្គកើតដំបៅ ហើយព្រះបច្ចេកពុទ្ធ១ព្រះអង្គក៏និមន្តទៅ ស្វែងរកទឹកឃ្មុំមកលាយថ្នាំព្យាបាល ។ ព្រះបច្ចេកពុទ្ធអង្គនោះហោះទៅចុះ ត្រង់មាត់កំពង់ទឹក១ ឃើញនាងកុម្ភទាសីម្នាក់ ចុះមកដងទឹកបានសួរថា នៅទីនេះមាននរណាមានទឹកឃ្មុំ អាត្មានឹងសុំគេយកទៅលាយថ្នាំ ព្យាបាលដំបៅអោយព្រះបច្ចេកពុទ្ធ១អង្គ នៅឯភ្នំគន្ធមាទន៍ឯណោះ។ នាងកុម្ភទាសីនោះ បានលើកដៃចង្អុលបង្ហាញថា "នុ៎ះហ្ន៎ ផ្ទះមធុពាណិជអ្នកលក់ទឹកឃ្មុំ សូមនិមន្តទៅសុំគេចុះ ទោះបានក្តី មិនបានក្តី សូមនិមន្តមកប្រាប់ខ្ញុំព្រះករុណាផង "។

There were many wise people residing on Kunthameat Mountain. One among the wise people suffered from a wound. Meanwhile, another wise person went to find honey to be used as a remedy. The aforesaid wise person flew down and stopped at a riverbank and saw a female pottery worker come to draw water. "Does anyone here have honey? I would like to beg for some honey to be used as remedy to cure the wound of a wise person living on Kunthameat mountain over there", the wise person said. The female pottery worker pointed and said, " the honey seller's house is over there. You can go to ask for honey there. Whether you got it or not, please let me know."



កាលព្រះបច្ចេកពុទ្ធនិមន្តទៅដល់ផ្ទះមធុពាណិជ្ជបានសុំបិណ្ឌបាតគេៗ ជ្រះថ្លា បានយកទឹកឃ្មុំមកដាក់បាត្រ ហើយឃើញទឹកឃ្មុំពេញហៀរហូរចេញពី មាត់បាត្រ ចុះទៅក្រោមដោកដីមានក្លិនផ្សាយភាយទៅលើអាកាស ក៏សូមប្រាថ្នាថា "ដោយផលទឹកឃ្មុំច្រើនហៀរហូរទៅក្រោមដោកដី ទៅលើ ផ្ទុំក្លិនពេញអាកាសនេះ ក្នុងជាតិខាងមុខ សូមអោយខ្ញុំបានជា ស្តេចចក្រ មានអំណាចធំផ្សាយទៅក្នុងដី១ យោជន៍ លើអាកាស ១ យោជន៍ ។

When the wise person reached the honey seller's house, he asked to be offered the honey. The seller was generous and offered him the honey. While he saw that the honey offered overflowed from the bowl to the ground, drenching the ground and spreading the smell through the air, the honey seller made a wish: "with the generous overflowing honey drenching the ground and scenting the air, in the next life may I become a powerful king spreading 16 kilometres under the ground and 16 kilometres into the air".



ព្រះបច្ចេកពុទ្ធធ្វើអនុមោទនា ហើយក៏និមន្តត្រឡប់មកប្រាប់នាងកុម្ភទាសីវិញ។ នាងកុម្ភទាសីសួរថា "កាលមធុពាណិជ្ជប្រគេនទឹកឃ្មុំនោះ គេប្រាថ្នាម្តេចខ្លះ?"។ ព្រះបច្ចេកពុទ្ធប្រាប់ថា "គេប្រាថ្នាអោយបានជាស្តេចចក្រមានអំណាចទៅក្នុងដី ១យោជន៍ លើអាកាស ១យោជន៍ ។ នាងនោះនិមន្តលោកអោយរង់ចាំខ្លួន ទៅយកសំពត់សាដកថ្មីមកប្រគេនលោកដើម្បីអោយលោកយកទៅរុំដំបៅហើយនាងសុំប្រាថ្នា "ខ្ញុំសូមអោយបានជាទេពីមធុពាណិជ្ជ នៅពេលដែលគេបានជាស្តេចចក្រនោះ ។



The wise person expressed joy at this generosity. Then, he returned to tell the female pottery worker. "When the honey seller offered you the honey, what did he wish for?" asked the woman. The wise person said "he wished that he would become a powerful king spreading 16 kilometres under the ground and 16 kilometres into the air". She asked the wise person to wait for a moment. Then, she brought out a new cloth and offered it to the wise person so that he could use it to wrap the wound of the suffering wise person, wishing, "May I become the queen of the honey seller when he becomes the king".

មធុពាណិជ្ជ ក្នុងជាតិខាងមុខបានជាព្រះបាទធម្មាសោកនៅនគរ បាត លីបុត្រមជ្ឈិមប្រទេស ក្រោយវេលាពុទ្ធនិពាន្ទប្រមាណ២០០ឆ្នាំ ជាស្តេចចុល្លចក្រក្នុងជម្ពូទ្វីប មានអំណាចធំផ្សាយទៅក្នុងផែនដី និងលើអាកាស ១យោជន៍ៗមែន ពួកនាគនៅក្នុងសមុទ្រនិង ពួកទេវតានៅលើអាកាស បាននាំបណ្ណាការផ្សេងៗ មកថ្វាយព្រះអង្គ ទ្រង់ជាអគ្គពុទ្ធសាសនូបត្ថម្ភក៏ ។ល ។

In the next life, the honey seller truly became King Dhammasaok in the Middle Kingdom of Bat Libotra, around 200 years after Buddha reached nirvana, the King of the central continent of the seven continents surrounding Mount Meru had power that spread 16 kilometres under the ground and 16 kilometres into the air. The nagas living in the sea and the deities living in the sky brought various offerings to give to the King, the main supporter of Buddhism.



នាងកុម្ភទាសីបានជាព្រះនាងអសន្ធិមិត្តា ព្រះទេពីព្រះបាទធម្មាសោក ។ ដោយអំណាចផល កាលដែលនាងបានលើកដៃចង្អុល បង្ហាញផ្លូវព្រះបច្ចេកពុទ្ធទៅរកទឹកឃ្មុំនោះ ព្រះនាងមានរូបឆោមល្អណាស់ មានព្រះហស្ថស្រលូត ឥតសន្លាក់ឡើយ ។ ដោយហេតុព្រះនាងមានព្រះហស្ថស្រលូតឥតសន្លាក់នោះឯង បានជាមានព្រះនាមថា ព្រះនាងអសន្ធិមិត្តា ។ កាលដែលព្រះបាទអសោកមហារាជ បានសោយរាជ្យ ហើយពុំទាន់លើកនាងស្នំណាមួយអោយ ជាព្រះអគ្គមហេសីពេញទីនៅឡើយ ។



The female pottery worker then became the Queen, Aksanthimetta, of the King, Dhammasaok. Due to the power of her generosity, since she had pointed to show the direction where the wise person would find honey, she was very beautiful with smooth, straight and clean arms. Since she had straight and clean arms, she was called Queen Aksanthimetta. When the Maharajah King Aksaok was reigning, he had not yet appointed any of his concubines to be his queen.

ថ្ងៃមួយព្រះនាងអសន្ធិមិត្តាទតតាមបង្អួចទៅ ឃើញទេវតាយកអំពៅ១ដើម ពីព្រៃហិមពាន្តមកថ្វាយព្រះនាង។ កំពុងតែសោយអំពៅនោះ ព្រះបាទធម្មាសោក ស្តេចចូលទៅក្នុងបន្ទប់នាង ទ្រង់ទតឃើញព្រះនាង សោយអំពៅទ្រង់សួរថា "ម្តេចក៏នាងសោយអំពៅ មានសាច់រឹងដូច្នោះ?"។ ព្រះនាងក្រាបទូលថា "ខ្ញុំម្ចាស់ទទួលព្រះរាជទានលមើល ព្រោះ អំពៅនេះកើតដោយបុណ្យរបស់ខ្ញុំម្ចាស់"។ ព្រះរាជាឮថាអំពៅ កើតឡើង ដោយបុណ្យរបស់នាង ក៏ទ្រង់ ពិរោធខ្លាំងណាស់។ ត្រាស់ថា:



One day, [when she was still just the] princess, Aksanthimetta looked through the window and saw a deity bringing sugarcane from Himalayas forest to offer her. While she was eating the sugarcane, King Dhammasaok entered the room, saw her eating the sugarcane, and asked her: "Why do you eat the sugarcane with hard flesh?" The queen replied: "I try to eat this sugarcane because it came from my good deed." When the king heard that the sugarcane came from her gooddeed, he was very angry and said:



បើដូច្នេះព្រឹកស្អែកឡើង យើងនឹងនិមន្តព្រះសង្ឃ ៥០០អង្គ មកឆាន់ក្នុងព្រះរាជវាំង ហើយយើងនឹងប្រគេនចីវរ១ត្រៃមួយអង្គ តែអោយនាងឯងរកចីវរដែលកើតអំពីបុណ្យខ្លួនប្រគេនលោក មិនបានគ្រប់៥០០ត្រៃសម្រាប់ប្រគេនលោក ១ត្រៃ១អង្គក្នុងថ្ងៃស្អែកនេះ យើងនឹងសម្លាប់នាងឯងពុំខាន ។ កាលបានទ្រង់ព្រះសណ្តាប់ដូច្នោះ យប់នោះព្រះនាងផ្ទំពុំលក់សោះ ទ្រង់គង់នៅមាត់បង្អួច បួងសួងរកព្រេងវាសនា ពីបុព្វជាតិ ។

"If so, tomorrow morning, I will invite 500 monks to eat in the royal palace, and I will offer three pieces of clothing for each monk, but I order you to find the monks' clothing made from your good deed to offer to the 500 monks. If tomorrow you cannot find enough pieces of monks' clothing to be offered to the 500 monks, I will kill you". When she heard that, she could not sleep. She stayed near the window and prayed using her faith in her good deeds from the previous life.







គ្រានោះដោយអំណាចផលទានដែល ព្រះនាងបានថ្វាយសំពត់សាដក ដល់ព្រះបច្ចេកពុទ្ធ ដើម្បីអោយលោកយកទៅរុំដំបៅពីជាតិមុននោះ ក៏ក្ដៅដល់អាសនព្រះឥន្ទ្រ ៗបានអោយទេវបុត្រ១អង្គ យកប្រអប់ទិព្វតូច១ ពេញដោយត្រៃចីវរមកថ្វាយព្រះនាង ហើយទេវបុត្រនោះបើកមាត់ប្រអប់បន្តិចឡើងហូតយកជាយចីវរបន្តិចបង្ហាញព្រះនាងថា "នេះជាប្រអប់ដាក់ត្រៃចីវរដែលកើតពីផលទានរបស់ព្រះនាង កាលដែលនៅជានាងកុម្ភទាសី បានថ្វាយសំពត់សាដកដល់ព្រះច្ចេកពុទ្ធ អោយលោកយកទៅរុំដំបៅនោះ សូមព្រះនាងហូតយកចីវរ១ត្រៃម្ដង១ប្រគេនព្រះសង្ឃ ១អង្គ១ត្រៃ គ្រប់៥00អង្គចុះ ហើយបើទ្រង់ចង់ហូតយកក្រៅពីនេះទៀតក៏បានតាមព្រះទ័យ ព្រះនាងទទួលប្រអប់នោះដោយសេចក្ដីរីករាយឥតឧបមា ។

At that moment, from the power of her generosity for offering the cloth to the wise person so that the wise person brought it to bind the wound of another suffering wise person in the previous life, so the Indra felt hot, the Indra therefore ordered a male divinity to bring her a small magic box full of pieces of clothing. Then, the male divinity opened the box slightly and took out the hem of the clothing to show her and said: "this is the box of pieces of clothing made from your good deed, when you, as a female pottery worker, offered the clothing to the wise person so that he could use it to bind the wound of the suffering wise person. You can take out three pieces of clothing each time to offer to each monk until you have done this for 500 monks, and if you want to take out more than this number, you can do it if you wish". She received that magic box with the greatest pleasure.



ព្រឹកស្អែកឡើង ព្រះរាជាទ្រង់ព្រះរាជបញ្ជាអោយសេវកាមាត្យ រៀបចំនិមន្តព្រះសង្ឃ ៥០០ អង្គមកឆាន់ ។ កាលព្រះអង្គឆាន់ហើយ ទ្រង់ហៅព្រះនាងអសន្ធិមិត្តា អោយយកត្រៃចីវរមកប្រគេនលោក ។ ព្រះនាងក៏កាន់ប្រអប់ទិព្វនោះហូតយកចីវរ១ត្រៃៗ ថ្វាយព្រះរាជាៗទ្រង់ប្រគេនព្រះសង្ឃ ១អង្គ១ត្រៃៗ គ្រប់៥០០អង្គ ។ ហើយព្រះនាងហូតយក សំពត់១អាវៗ ថ្វាយព្រះរាជវង្សានុវង្ស គ្រប់អង្គនិងមន្ត្រីគ្រប់រូបដែល មកក្នុង



មហាសន្និបាតនោះថែមទៀត ។ ព្រះមហាក្សត្រទ្រង់ឃើញនូវអព្ភូតហេតុ ដ៏អស្ចារ្យដូច្នោះទ្រង់ក៏លើក ព្រះនាងអសន្ធិមិត្តាជាអគ្គមហេសីពេញទី ។

The next morning, the King ordered his servants to be prepared to invite 500 monks to eat at the royal palace. After the 500 monks finished eating, the King ordered Princess Aksanthimetta to bring three pieces of clothing to offer to each monk. She held the small magic box, taking out three pieces of clothing for the King to offer to each monk. The King offered three pieces of clothing to each of 500 monks. Then she took out one cloth and one shirt for each royal personage as well as all the officials attending the general meeting. When the King saw this miraculous event, he officially appointed Princess Aksanthimetta as his queen.



ថ្ងៃក្រោយទ្រង់ជ្រាបថា នាងស្នំឯទៀតច្រណែនខ្លាំង ក៏ទ្រង់ព្រះបញ្ជាឱ្យ
នាយពិសេសធ្វើនំបំពួនស្ករគ្រប់តាមចំនួននាងស្នំដែលមានប៉ុន្មាន
ទ្រង់ដាក់នំនោះក្នុងភាជន៍ធំរួចអោយបង្កប់ព្រះទម្រង់ដ៏មានតម្លៃ
ជាស្នូលក្នុងនំ១ដាក់លើគេបង្អស់ មិនអោយនាងណាដឹងឡើយហើយអោយ
នាងស្នំឯទៀតចាប់មុន នៅសល់តែនំមួយ ទើបទ្រង់អោយព្រះនាង
អសន្និមិត្តាចូលចាប់ ក្រោយគេ បំផុត ហើយទ្រង់អោយ



នាងស្នំទាំងអស់ចាប់បើកនំដំណាលគ្នាកណ្ដាលជំនុំ ។ នាងស្នំឯទៀតៗ បើកនំឡើងមិនឃើញព្រះទម្រង់សោះ ។ ឯព្រះនាងអសន្ធិមិត្តាទ្រង់ បើកឡើងឃើញ ព្រះទម្រង់ភ្លឺផ្លេកៗនៅក្នុងនោះជាមហាស្ចារ្យ ។

After that, the King realized that his other concubines in the palace were very jealous, so he ordered his special servant to make cakes consisting of a piece of sugar wrapped in a layer of sticky rice flour as per the number of his concubines. He put those cakes on a large plate. Then, he hid a precious ring inside one cake putting it the top, but letting no concubine know about this. The King ordered the other concubines each to pick a cake first until the remaining one was for Princess Aksanthimetta. The King ordered all the concubines to open their cakes at the same time during the gathering. Those concubines opened the cakes without any ring, whereas Princess Aksanthimetta opened her cake and saw the bright ring inside.





កាលទ្រង់ពិសោធរកព្រេងវាសនា របស់ព្រះនាងអសន្ធិមិត្តាឃើញច្បាស់ ហើយក៏ទ្រង់ប្រកាសកណ្តាលមហាសន្និបាតថា "នេះហើយជាភ័ព្វវាសនា របស់នាងអសន្ធិមិត្តាដែលគេបានសាងពីបុព្វជាតិមក ត្រូវបានជាអគ្គមហេសីរបស់យើងចូរនាងស្នំឯទៀតៗ ជឿវាសនារបស់គេចុះ កុំច្រណែននឹងគេឡើយ" ។

As the King clearly could clearly see the predestined fate of Princess Aksanthimetta through this experiment, he declared during the general meeting: "this is the predestined good fortune of Aksanthimetta that she made in her previous life, so she deserves the title of my queen, so please, other concubines, believe in her fate and do not be jealous of her."



លុះបានជាព្រះអគ្គមហេសីពេញទីហើយ ព្រះនាងអសន្ធិមិត្តាក៏ទ្រង់សោយ ព្រះបរមសុខក្នុងព្រះសិរីរាជសម្បត្តិក្រោមម្លប់ព្រះសម្ភារបារមីនៃ ព្រះបាទធម្មាសោកមហារាជាធិរាជ ជាស្ដេចចុល្លចក្រនៅជម្ពូទ្វីប ដរាបដល់អស់ព្រះជន្មបានទៅកើតក្នុងទេវលោក ។

After her coronation as the queen, Queen Aksanthimetta enjoyed the bliss of royal wealth under the shelter of the accumulated goodness of Maharajah King Dhammasaok, the King of the central continent of the seven continents surrounding Mount Meru, until her death, before her next incarnation in heaven.

